ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
អគ្គលេខាធិការដ្ឋាន
លេខ:.០១៣.សរ៥៣អ.ក.អ.ច.

# សេចក្តីប្រកាសព័ត៌មាន
## សទ្ទានុក្រមការប្រែប្រួលអាកាសធាតុជាខេមរភាសា ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព មានកិត្តិយសសូមជម្រាបជូនសាធារណជន និងបណ្តាញសារព័ត៌មានជាតិនិងអន្តរជាតិ ឱ្យបានជ្រាបថា ក្រសួងបរិស្ថាន ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងក្រុមប្រឹក្សាជាតិភាសាខ្មែរ បានរួមគ្នាប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **"សទ្ទានុក្រមការប្រែប្រួលអាកាសធាតុជាខេមរភាសា ទាំងជាសៀវភៅនិងជាទម្រង់អេឡិចត្រូនិច"** ដំបូងបង្អស់ក្នុងវិស័យប្រែប្រួលអាកាសធាតុ នៅរសៀលថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ នៅទីស្តីការក្រសួងបរិស្ថាន សម្រាប់សាធារណជន និងអ្នកប្រើប្រាស់គ្រប់មជ្ឈដ្ឋាន ដើម្បីជាជំនួយដល់ការប្រើប្រាស់បច្ចេកសព្ទក្នុងវិស័យប្រែប្រួលអាកាសធាតុ ប្រកបដោយភាពត្រឹមត្រូវ សង្គតិភាព និងឯកភាព។

ថ្លែងក្នុងពិធីបើក ឯកឧត្តម **សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាននិងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានគូសបញ្ជាក់ថា «កិច្ចសហការរវាងស្ថាប័នជំនាញផ្នែកបរិស្ថាននិងការប្រែប្រួលអាកាសធាតុ ព្រមទាំងស្ថាប័នជំនាញផ្នែកភាសាខ្មែរដើម្បីផលិតសទ្ទានុក្រមការប្រែប្រួលអាកាសធាតុ គឺជាកិច្ចការដ៏មានតម្លៃ សម្រាប់កូនចៅជំនាន់ក្រោយរបស់យើង មិនត្រឹមតែផលិតជាសៀវភៅសម្រាប់អានប្រកបដោយភាពត្រឹមត្រូវតាមសម្ព័ន្ធភាសាខ្មែរប៉ុណ្ណោះទេ ថែមទាំងជាទម្រង់អេឡិចត្រូនិចដែលអាចទាញយកមកប្រើជាមួយទូរស័ព្ទដៃ និងកុំព្យូទ័រ ដែលនេះគឺជាជំហានថ្មីមួយបញ្ជាក់ពីការអភិវឌ្ឍសមត្ថភាពជំនាញឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់ជាតិ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។»

ឯកឧត្តមរដ្ឋមន្ត្រី បានជំរុញឱ្យស្ថាប័នជំនាញពាក់ព័ន្ធទាំងអស់ប្រើប្រាស់បច្ចេកសព្ទដែលមានក្នុងសទ្ទានុក្រមនេះ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីមេពាក្យ និងសេចក្តីពន្យល់នៃមេពាក្យនីមួយៗ សំដៅអភិវឌ្ឍចំណេះដឹងនិងផ្នែកស្រាវជ្រាវកាន់តែមានប្រសិទ្ធភាពខ្ពស់ និងមានការឯកភាពគ្នានៅក្នុងប្រទេសយើង។

ឯកឧត្តមបណ្ឌិត **ច័ន្ទ សំណាង** ប្រធានក្រុមប្រឹក្សាជាតិភាសាខ្មែរ និងជាអនុប្រធានរាជបណ្ឌិត្យសភាកម្ពុជា ក៏បានបញ្ជាក់ថា «សទ្ទានុក្រមការប្រែប្រួលអាកាសធាតុ គឺជានិមិត្តរូបនៃការធ្វើខ្មែរនីយកម្មលើបច្ចេកសព្ទនៃភាសាបរទេស ដើម្បីឱ្យកូនខ្មែរបានប្រើប្រាស់ប្រកបដោយការឯកភាពគ្នា ដែលប្រការនេះស្តែងពីកាយវិការដ៏វិជ្ជមានមួយក្នុងការរួមចំណែកក្នុងការអភិរក្សនិងអភិវឌ្ឍភាសាខ្មែរប្រកបដោយការទទួលខុសត្រូវខ្ពស់»។ ឯកឧត្តមបណ្ឌិតបានបន្តថា នឹងដាក់បញ្ចូលបច្ចេកសព្ទទាំងនេះទៅក្នុងវចនានុក្រមជាតិភាសាខ្មែរ ដែលនឹងត្រូវបោះពុម្ពនិងប្រកាសឱ្យប្រើជាផ្លូវការនៅឆ្នាំ២០២២ខាងមុខ។

លោកជំទាវឯកអគ្គរាជទូតប្រទេសស៊ុយអែតប្រចាំនៅកម្ពុជា និងជាតំណាងម្ចាស់ជំនួយរបស់កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា Maria Sargren បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលស៊ុយអែតមានក្តីសោមនស្សដោយបានសហការជាមួយរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសលើផ្នែកប្រែប្រួលអាកាសធាតុ។ សទ្ទានុក្រមនេះ នឹងក្លាយទៅជាឧបករណ៍ដ៏មានតម្លៃសម្រាប់បង្កើនចំណេះដឹងដល់អ្នកសិក្សាស្រាវជ្រាវ និងប្រតិបត្តិករលើផ្នែកប្រែប្រួលអាកាសធាតុនៅកម្ពុជា។

សទ្ទានុក្រមការប្រែប្រួលអាកាសធាតុនេះ មានបច្ចេកសព្ទសរុបចំនួន**៤៤៦មេពាក្យ និងអក្សរកាត់ ១៣២ពាក្យ**។ ដើម្បីទាញយកappមកប្រើប្រាស់នៅក្នុងទូរស័ព្ទដៃ សូមចូលទៅក្នុង App Store ឬ Play Store វាយពាក្យ CCLexicon និងដំឡើង។ ហើយក៏អាចចូលមើលនៅក្នុងគេហទំព័រនាយកដ្ឋានប្រែប្រួលអាកាសធាតុ www.camclimate.org.kh។

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧

***ព័ត៌មានបន្ថែម សូមទាក់ទង :***
លោកបណ្ឌិត ហេង ចាន់ធឿន
អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ
ទូរស័ព្ទ៖ +855 16 726 668
អ៊ីម៉េល៖ hcthoeuncc@gmail.com